

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# បាឋកថាស្តីពី

## "យល់ដឹងពីស្ថានការណ៍ពិភពលោកបច្ចុប្បន្ន និង ការរៀបចំនយោបាយការបរទេសរបស់កម្ពុជា"

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន
រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

14/09/2017 at Royal School of Administration

# ផ្នែកធំ ២៖



## I- ស្ថានការណ៍ពិភពលោកបច្ចុប្បន្ន

## II- ការរៀបចំនយោបាយការបរទេសរបស់កម្ពុជា

ត្រូវយល់ច្បាស់ពីស្ថានភាព និងនិន្នាការធំៗនៃពិភពលោកបច្ចុប្បន្ននេះ ដើម្បីតាក់តែងរៀបចំឲ្យបានត្រឹមត្រូវ នយោបាយការបរទេសរបស់ខ្លួន។

# I- ស្ថានការណ៍ពិភពលោកបច្ចុប្បន្ន



- ការបញ្ចប់នៃសង្គ្រាមលោកលើកទី ២ (WWII)អាចយកមកធ្វើជាចំណុចដៅដើម្បីនិយាយ និងងាយយល់ពីប៉ូលកម្លាំង
- ជ័យជំនះរបស់ប្រទេសសម្ព័ន្ធមិត្ត បាននាំដល់ការបែងចែកអំណាចរវាងអ្នកឈ្នះសង្គ្រាម
- ការប្រកួតប្រជែងអំណាច និងឥទ្ធិពល ការមិនទុកចិត្តគ្នារវាងមហាអំណាចធំទាំងពីរនាសម័យកាលនោះ គឺសហរដ្ឋអាមេរិក និងសហភាពសូវៀតបាននាំដល់កកើតនៃប៉ូល ២ (កើត-លិច) ដែលដឹកនាំដោយមនោគមវិជ្ជា ២ (សង្គមនិយម-មូលធននិយម) និងការប្រឈមមុខដាក់គ្នានៃប្លុកយោធា២ (កតិកាសញ្ញា Warsaw-NATO)
- ពិភពលោកក្នុងសម័យកាលនោះបានធ្លាក់ចូលក្នុងសង្គ្រាមត្រជាក់ដែលរលត់ទៅវិញនៅឆ្នាំ១៩៩១ ពេលសហភាពសូវៀតដួលរលំ

- ក្នុងរយៈពេលជាង២៦ឆ្នាំ បន្ទាប់ពីការបញ្ចប់សង្គ្រាមត្រជាក់ មានការប្រែប្រួលដ៏ជ្រាលជ្រៅនៃតុល្យការកម្លាំង ការរៀបចំឡើងវិញនូវប្រព័ន្ធអភិបាលកិច្ចពិភពលោកដែលទទួលឥទ្ធិពលពីការប្រែប្រួលកម្លាំងទាំងនោះ ពីការងើបឡើងនៃតួអង្គថ្មី ពីការប្រឈមនានា និងសមរភូមិភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ទេសន្តប្រវេសន៍ គ្រោះមហន្តរាយ ការប្រែប្រួលធាតុអាកាស និងជំងឺឆ្លងនានា ដែលត្រូវជំនះ ។

# ក្នុងរយៈពេលជាង ២៦ឆ្នាំ បន្ទាប់ពីការបញ្ចប់សង្គ្រាមត្រជាក់៖



(១)មានការប្រែប្រួលដ៏ជ្រាលជ្រៅនៃតុល្យការកម្លាំង ការរៀបចំឡើងវិញនូវប្រព័ន្ធអភិបាលកិច្ចពិភពលោកដែលទទួលឥទ្ធិពលពីការប្រែប្រួលកម្លាំងទាំងនោះ

(២)ពីការងើបឡើងនៃតួអង្គថ្មីៗ

(៣)ពីការប្រឈមនានា និងសមរភូមិភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ទេសន្តប្រវេសន៍ គ្រោះមហន្តរាយ ការប្រែប្រួលធាតុអាកាស និងជំងឺឆ្លងនានាដែលត្រូវជំនះ ។

# (១) មានការប្រែប្រួលដ៏ជ្រាលជ្រៅនៃតុល្យភាពកម្លាំង៖

- ២៦ឆ្នាំក្រោយពីបានយកឈ្នះលើអតីតសហភាពសូវៀត ឧត្តមភាពត្រួតត្រារបស់សហរដ្ឋអាមេរិកនៅតែធំធេង ប៉ុន្តែ ឧត្តមភាពនេះត្រូវទទួលរងការប្រកួតប្រជែង។
- អាមេរិកនៅតែមានឧត្តមភាពលើសគេ ខាងនយោបាយ យោធា សេដ្ឋកិច្ច បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងវប្បធម៌ ។
- ប៉ុន្តែ អាមេរិករងនូវវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបំណុលសាធារណៈដែលបណ្តាលមកពីការជាប់ផុងក្នុងសង្គ្រាមនៅអ៊ីរ៉ាក់ និងអាហ្វហ្គានីស្ថាន ជាង១០ឆ្នាំ។
- អាមេរិកចុះខ្សោយ ឯប្រទេសផ្សេងទៀតក៏ឡើងខ្លាំង ។

 

# យករឿងកំប្លែងសាមញ្ញមួយមកធ្វើការវិភាគ ៖



- អាជ័យរត់បានលេខ២ ក្នុងចំណោមអ្នករត់២នាក់ ៖ មានន័យដូចម្តេច?
- ត្រូវវិភាគឲ្យគ្រប់ជ្រុងជ្រោយ តាមការរកមូលហេតុគ្រប់យ៉ាង ។
- អ្វីៗត្រូវធ្វើការប្រៀបធៀប៖ លេខ២ ក្នុងថ្នាក់? ក្នុងសាលា? ក្នុងខេត្ត? ក្នុងប្រទេស?
- មុននេះធ្លាប់រត់បានលេខប៉ុន្មាន? ឡើង? ចុះ?
- កត្តាផ្សេងៗ៖ សុខភាព - អាហារ - កត្តាក្រៅ (តំរាម? ស៊ីសំណូក)
- ការងើបឡើងរបស់អ្នកដ៏ទៃ៖ អ្នកនោះកាន់តែខ្លាំងជាងមុន ហើខ្លាំងជាងខ្លួនយើង។

- ក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ នៅពេលសេដ្ឋកិច្ចនៃប្រទេសឧស្សាហកម្មធំៗមានការថមថយ ប្រទេសផ្សេងទៀតពិសេស BRICS មានកំណើនសេដ្ឋកិច្ចដ៏ខ្ពស់ និងថេរមិននឹកស្មានដល់ ទោះក្នុងដំណាក់កាលវិបត្តិពិភពលោកក៏ដោយ ។
- តុល្យការនៃកម្លាំងបានប្រែប្រួលយ៉ាងពិតប្រាកដ ។

# (២) ការងើបឡើងនៃតួអង្គថ្មីនៃពិភពលោក



- គឺតួអង្គជាមហាអំណាចដែលបានរះឡើង ឬ រះឡើងជាថ្មី ហើយដែលបង្ហាញឲ្យឃើញថា ពេលនេះគេមានទម្ងន់ខាងនយោបាយ សេដ្ឋកិច្ច យោធាគ្រប់គ្រាន់ ដើម្បីតថ្លៃ ទាមទារឲ្យរាល់ការសម្រេចលើកិច្ចការសំខាន់ៗនៃពិភពលោក ត្រូវតែមានគេចូលរួម ។
- តួអង្គ(រដ្ឋ)នោះសំខាន់ជាងគេគឺ BRICS: Brazil, Russia, India, China និង South Africa ។

# រុស្ស៊ី៖



- ការងើបឡើងវិញនៃមហាយក្ស ក្រោមរជ្ជកាល Putin II
- មហាអំណាចនុយក្លេអ៊ែរទី ២, មហិច្ឆតាមិនលាក់លៀម, ចេញយន្តហោះចម្បាំងផុតពីដែនអាកាសរបស់ខ្លួន, នាវាមុជទឹកល្បាតគ្រប់មហាសមុទ្រ, ធ្វើ អន្តរាគមន៍នៅ Georgia, បញ្ចេញជំហរតតាំងសង្គ្រាមនៅ Syria, បញ្ហានុយក្លេអ៊ែរនៅ Iran, យកតំបន់Crimea ចូលទឹកដីរុស្ស៊ីវិញតាមរយៈប្រជាមតិ, អន្តរាគមន៍នៅ Ukraine តបនឹងការផ្តួលរបបមុនតាមបដិវត្តពណ៌, បង្កើត AEEU…
- លែងខ្ចីលុយអាមេរិកដូចបណ្តាឆ្នាំ ៩០ ហើយមានចំណូលសន្ធឹកពីប្រេង និងឧស្ម័ន ។
- ទណ្ឌកម្មសេដ្ឋកិច្ច កាន់តែបង្ខិតរុស្ស៊ីមកជិតនឹងចិន ។

# ចិន៖





- Deng Xiaoping ជម្រុញកំណែទម្រង់ទំនើបកម្ម៤យ៉ាងនៅឆ្នាំ១៩៧៨ (កសិកម្ម ឧស្សាហកម្ម ការពារជាតិ និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា)
- កំណើន +៩% ក្នុងរយៈពេលជាង ៣០ឆ្នាំ
- មនុស្ស ៤-៥០០លាននាក់ ចាកផុតពីភាពក្រីក្រ
- មានប្រជាជនច្រើនជាងគេ
- អំណាចសេដ្ឋកិច្ចទី ២
- ទុនបម្រុងរូបិយវត្ថុបរទេសធំជាងគេ
- កងទ័ពធំជាងគេ ចំណាយយោធាកើន និងមានលំដាប់លេខ ២ លើពិភពលោក (២០១៤: ១៧១ប៊ីលាន ២០១៥: ១៩០ប៊ីលាន ២០១៦: ២១៥ប៊ីលាន)
- បច្ចេកវិទ្យាកាន់តែខ្លាំង៖ ផលិតយន្តហោះ រថយន្ត ផ្កាយរណប គ្រឿងអេឡិចត្រូនិក.....
- មានរោងចក្រច្រើនជាងគេ
- ទីក្រុង២០ ដែលលូតលាស់លឿនជាងគេលើពិភពលោក ស្ថិតនៅចិនទាំងអស់ ។
- " ប្រទេសចិនខ្លាំង នឹងផ្តល់ផលប្រយោជន៍ច្រើនដល់សហគមន៍ពិភពលោក ដូចជាការវិនិយោគកាន់តែច្រើនដោយក្រុមហ៊ុនចិន

# ក៏មានតួអង្គមិនមែនរដ្ឋដែរ៖



- អង្គការភេរវកម្ម និងឧក្រិដ្ឋកម្មនានា
- សង្គមស៊ីវិល (NGOs) ដែលមានតួនាទីកាន់តែធំឡើងៗ ក្នុងគ្រប់វិស័យនៃកិច្ចការជាតិ ។

# (៣)សមរភូមិភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ការបន្លាស់ទី គ្រោះមហន្តរាយ ការប្រែប្រួលធាតុអាកាស ជំងឺឆ្លង នានាដែលត្រូវជំនះ ។



- ISIS ៖ ក្រុមភេរវកម្មបានប្រែធាតុ មានទឹកដី មានកងទ័ព មានធនធានហិរញ្ញវត្ថុ ។
- វិបត្តិជនភៀសខ្លួនដែលហូរចូលក្នុងទឹកដីអឺរ៉ុប គេចពីសង្គ្រាម
- គ្រោះមហន្តរាយធម្មជាតិ ឬ បង្កដោយមនុស្ស

# សន្និដ្ឋាន៖



- ពិភពលោកសព្វថ្ងៃប្រែប្រួលយ៉ាងស្មុគ្រស្មាញ ប្រឈមនឹងភាពមិនច្បាស់លាស់ជាច្រើន
- ការចុះខ្សោយនៃលោកខាងលិច (អឺរ៉ុបដែលធ្លាប់ជាមហាអំណាចដឹកនាំពិភពលោកក៏ជួបនឹងវិបត្តិច្រើន និងស្មុគស្មាញមាន Brexit, វិបត្តិប្រាក់Euro, វិបត្តិជនភៀសខ្លួន, រងការវាយប្រហារដោយភេរវកម្ម, … )
- ជញ្ជីងធ្ងន់មកខាងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដឹកនាំដោយការរះឡើងរបស់ចិន ។
- ការងើបឡើងយ៉ាងពិតប្រាកដរបស់ BRICS ដែលពង្រឹងនិន្នាការពហុប៉ូល ។
- មានតំបន់ក្តៅ និងប្រកបដោយហានិភ័យជាច្រើន (មជ្ឈឹមបូព៌ា និងអាហ្វ្រិក)
- ការថយក្រោយនៃសណ្តាប់ធ្នាប់អន្តរជាតិ (ដែលបង្កើតឡើងក្រោយ WWII)
- និងមានការប្រឈមធំៗជាច្រើន ដែលត្រូវដោះស្រាយរួមគ្នា ។
- ពិភពលោកសព្វថ្ងៃក៏មានចរិតសកល មានការតភ្ជាប់ និងពឹងពាក់គ្នាកាន់តែខ្លាំង ហើយទីផ្សារមានអំណាចឥទ្ធិពលនាំមុខគេ ។

# II- តើត្រូវរៀបចំនយោបាយការបរទេសបែបណាសម្រាប់កម្ពុជា ?



- នយោបាយការបរទេសរបស់ប្រទេសណាក៏ដោយ តែងដើរតាមកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងផលប្រយោជន៍ជាតិនៃប្រទេសនោះ ។
- បន្ទាត់នយោបាយការបរទេសកម្ពុជាត្រូវបានចែងក្នុងមាត្រា ៥៣, ៥៤ និង៥៥ នៃរដ្ឋធម្មនុញ្ញ ។
- បន្ទាត់នយោបាយដែលត្រូវបានចែងនាឆ្នាំ ១៩៩៣ នៅតែជាគោលការណ៍គ្រឹះនៃនយោបាយក្រៅប្រទេសរបស់កម្ពុជា ទោះបីមានការប្រែប្រួលនៅលើពិភពលោក និងក្នុងប្រទេសរយៈពេលជាង ២០ឆ្នាំចុងក្រោយនេះក៏ដោយ ។
- ការកំណត់ និងអនុវត្តនយោបាយក្រៅប្រទេសនេះ នឹងកំណត់ទីតាំងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក ។

## ដើម្បីកំណត់បន្ទាត់នយោបាយក្រៅប្រទេស ជាពិសេសដើម្បីយល់អំពីកត្តា ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងភូមិសាស្ត្រ-នយោបាយ យើងត្រូវរកចម្លើយទៅនឹងសំណួរសាមញ្ញ៣គឺ៖



- យើងមកពីណា ?
- យើងស្ថិតនៅទីណា ?
- យើងចង់ (និង/ឬ អាច) ទៅទីណា ?

# (១) យើងមកពីទីណា?

- កម្ពុជារុងរឿងបំផុតគឺនៅសម័យអង្គរ (៨០២ ដល់ ១៤៣១)
- តែត្រូវហែកហួរផុនដាបធ្លាក់ចុះរាប់សតវត្ស សឹងរលាយ រហូតរកកិច្ចគាំពារពីបារាំង(១៨៦៣)
- ទទួលឯករាជ្យឆ្នាំ ១៩៥៣ ដោយស្នាព្រហស្ត៍របស់សម្តេចព្រះនរោត្តមសីហនុ
- ហែកហួរខ្ទេចខ្ទាំដោយសារសង្គ្រាម/របបប្រល័យពូជសាសន៍ជិត ៣ទសវត្ស
- ១៩៧៩-១៩៩៨៖ ទណ្ឌកម្មសេដ្ឋកិច្ច ឯកោ សង្គ្រាមស៊ីវិល ការចរចា កិច្ចព្រមព្រៀងក្រុងប៉ារីស UNTAC, Win-Win Policy សន្តិភាព និងការរួបរួមជាតិ
- ក្រោយថ្ងៃរំដោះ ១៩៧៩ នយោបាយការទូតរបស់យើងសំដៅស្វែងរកការគាំទ្រ ជំនួយបន្ទាន់ ជំនួយអភិវឌ្ឍន៍ ដើម្បីស្តារ និងកសាងប្រទេសជាតិឡើងវិញ និងរារាំងការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ។
- ក្រោយឆ្នាំ ១៩៩៨ ពេលមានសន្តិភាពពេញលេញ កម្ពុជាខិតខំធ្វើសមាហរណកម្មក្នុងតំបន់ និងពិភពលោក ដូចជា ចូលអាស៊ាន (១៩៩៩) ចូលជាសមាជិក WTO (២០០៤) ហើយក៏ដើរតួនាទីកាន់តែសកម្មក្នុងអង្គការតំបន់ និងពិភពលោក ។

# (២) យើងកំពុងស្ថិតនៅទីណា ?



- ពិនិត្យទម្ងន់របស់ប្រទេសយើង (ដែនដី ប្រជាជន សេដ្ឋកិច្ច យោធា....)
- ទើបចេញផុតពីឋានៈជាប្រទេសមានចំណូលទាប មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។ +៧% ជាមធ្យមជាង ២០ឆ្នាំចុងក្រោយនេះ ។
- ជាប្រទេសដែលកំពុងកសាង និងអភិវឌ្ឍ ដែលត្រូវការជាចាំបាច់នូវសន្តិភាព ស្ថិរភាព ដើម្បីពង្រឹងជំនឿទុកចិត្តដល់អ្នកវិនិយោគ ទាក់ទាញទេសចរណ៍ ។ល។
- គេស្គាល់ និងទទួលស្គាល់កម្ពុជាកាន់តែច្រើន ។

# (៣) តើយើងចង់ទៅណា? (អាចនឹងត្រូវទៅណា?)



- នយោបាយការបរទេសធ្វើឡើងដើម្បីបម្រើផលប្រយោជន៍ជាតិ ។
- ផ្អែកលើស្ថានភាពនៃពិភពលោក ផ្អែកលើតម្រូវការ សមត្ថភាព និងលទ្ធភាពរបស់យើងផ្ទាល់ នយោបាយការបរទេសត្រូវរៀបចំឡើងដើម្បីបម្រើផលប្រយោជន៍របស់ជាតិ និងប្រជាពលរដ្ឋកម្ពុជា គឺដើម្បីលើកស្ទួយ និងការពារអធិបតេយ្យ បូរណភាពទឹកដី ការពារសន្តិសុខជាតិ ស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច ។
- ដើម្បីសម្រេចគោលដៅនេះត្រូវ៖
  - ប្រែពីនយោបាយការទូតប្រពៃណីមកជានយោបាយការទូតដែលផ្ដល់សារៈសំខាន់ដល់សកម្មភាពសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ។
  - បំពេញតួនាទីកាន់តែសំខាន់ឡើងក្នុងបណ្ដាវេទិកាតំបន់ និងពិភពលោក ចូលរួមក្នុងស្ថាប័នអន្តរជាតិ អង្គការតំបន់នានា ដែលផ្ដល់ផលប្រយោជន៍ ។

- ផ្អែកលើស្ថិរភាពផ្ទៃក្នុង ខិតខំអនុវត្តគោលនយោបាយពង្រឹងទីផ្សារចាស់ ពង្រីកទីផ្សារថ្មី ខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគដើម្បីជំរុញការនាំចេញដែលនឹងទាញកំណើនការងារ ផលិតផល និង ចំណូលក្នុងស្រុក ។
- ពង្រឹងពង្រីកទំនាក់ទំនងខាងនយោបាយ និងសេដ្ឋកិច្ចជាមួយគ្រប់ប្រទេសទាំងអស់ ដោយឈរលើ គោលការណ៍គោរពគ្នាទៅវិញទៅមក គោរពអធិបតេយ្យភាព មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងផងគ្នា និង ដើម្បីផលប្រយោជន៍នៃប្រទេស និងប្រជាជនទាំងសងខាង ។
- កសាងតំបន់ព្រំដែនឲ្យទៅជាតំបន់សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ដោះស្រាយ បញ្ហាសេសសល់ដោយឈរលើគោលការណ៍ Uti Possidetis ច្បាប់អន្តរជាតិ និងសន្ធិសញ្ញា និងឯក សារនានាដែលបានព្រមព្រៀងគ្នា ។
- កសាងជួរមន្ត្រីការទូតដែលមានកម្រិតវិជ្ជាជីវៈខ្ពស់ សមត្ថភាពខ្ពស់ ជំហរការពារផលប្រយោជន៍ និង ស្វាមីភក្តិច្បាស់លាស់ រឹងមាំ មិនងាករេចំពោះជាតិមាតុភូមិ ជាយុទ្ធជនដ៏ប៉ិនប្រសប់ និងមុតស្រួចលើ សមរភូមិការទូត ។

# សន្និដ្ឋានៈ



- បន្តបន្ទាត់នយោបាយក្រៅប្រទេសដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ
- ពង្រឹងមិត្ត+ទីផ្សារចាស់ ពង្រីកមិត្ត+ទីផ្សារថ្មី ផ្អែកលើមូលដ្ឋាននៃការគោរពគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍ទាំងសង្ខាង
- ពង្រីកសកម្មភាពការទូតឆ្ពោះទៅរកវិស័យ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ និងទេសចរណ៍
- លើកកំពស់កំរិតសមត្ថភាព វិជ្ជាជីវៈរបស់មន្ត្រីការទូត ឲ្យក្លាយជាយុទ្ធជនជំមុតស្រួចក្នុងការការពារផលប្រយោជន៍ជាតិលើឆាកអន្តរជាតិ។

# សំណួរ - ចម្លើយ



# សូមអរគុណ!

## ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

